មជ្ឈមណ្ឌលឯកសារកម្ពុជា

**BMI0167**

# សម្ភាសជាមួយឈ្មោះ ទិត ណេង ភេទស្រី អាយុ៥២ឆ្នាំ
# មុខងារខ្មែរក្រហមៈ “ប្រជាជនធ្វើការនៅកងចល័ត”
# រស់នៅភូមិប៉ោយសំរោង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ
# ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១
# សម្ភាសន៍ដោយៈ ឡុង ដានី
# ០០:៣២:១៧
# ១៩ទំព័រ

ដានី : ដំបូងមីងខ្ញុំចង់ស្គាល់ឈ្មោះមីង?

ណេង : ខ្ញុំ ទិត ណេង ។

ដានី : ឈ្មោះ ទិត ណេង?

ណេង : ចា៎!

ដានី : មីងសព្វថ្ងៃអាយុប៉ុន្មានហើយ?

ណេង : ខ្ញុំឆ្នាំជូតនោះ ៥២ហើយ ។

ដានី : អាយុ៥២?

ណេង : ចា៎!

ដានី : ស្រុកកំណើតកើតជា នៅភូមិឃុំស្រុកអីដែរ?

ណេង : ខ្ញុំនៅស្រុកព្រះនេត្រព្រះ ឃុំព្រះនេត្រព្រះ ម៉ែឪខ្ញុំនៅនេះ នេះផ្ទះម្ដាយមីង ។

ដានី : ស្រុកកំណើតកើតជានៅភូមិអី?

ណេង : នៅភូមិព្រះនេត្រព្រះ ។

ដានី : នៅភូមិព្រះនេត្រព្រះ?

ណេង : ប៉ោយសំរោង ។

ដានី : ភូមិប៉ោយសំរោង?

ណេង : ខ្សាច់ហួត ត្រង់នេះគេហៅខ្សាច់ហួត ។

ដានី : កាលពីដើមដែលមីងកើតជាគេហៅភូមិអី?

ណេង : ភូមិប៉ោយសំរោង ។

ដានី ៖ ភូមិប៉ោយសំរោង?

ណេង ៖ ចាំ! ដល់ខ្ញុំកើតឡើងមក ដឹងចល័តមក គេយកខ្ញុំដាក់ត្រពាំងថ្ម ។

ដានី ៖ ចុះឃុំអីទៅប៉ោយសំរោង?

ណេង ៖ ឃុំព្រះនេត្រព្រះ ។

ដានី ៖ ស្រុកអីដែរ?

ណេង ៖ ស្រុកព្រះនេត្រព្រះដូចគ្នា ។

ដានី ៖ ខេត្ត?

ណេង ៖ ខេត្តខត្តរមាន ។

ដានី ៖ ខេត្តបន្ទាយមានជ័យ?

ណេង ៖ អឺ! ខេត្តបន្ទាយមានជ័យ ។

ដានី ៖ ចុះមីងសព្វថ្ងៃរស់នៅភូមិអីដែរ?

ណេង ៖ ភូមិនេះឯង កូននៅផ្ទះខ្ញុំ កូនតូចញ៉ែប ។

ដានី ៖ រស់នៅភូមិនឹងគេហៅភូមិអី?

ណេង ៖ ភូមិខ្សាច់ហូរ ។

ដានី ៖ ភូមិខ្សាច់ហូរ មិនមែនភូមិប៉ោយសំរោង?

ណេង ៖ ទេ! ភូមិប៉ោយសំរោង តែត្រង់នេះគេហៅភូមិខ្សាច់ហូរបានចេះគេរកឃើញ ថាយាយណេងៗ ភូមិខ្សាច់ហូរចេះ គេឆាប់រកឃើញ ។

ដានី ៖ ប៉ុន្តែជាទូទៅគេហៅភូមិអី?

ណេង ៖ ភូមិប៉ោយសំរោង ។

ដានី ៖ ប៉ុន្តែគេហៅខ្សាច់ហូរ?

ណេង ៖ ចាំ! អានេះគេឆាប់រកឃើញ ។

ដានី ៖ ឃុំគេនឹង?

ណេង ៖ ឃុំព្រះនេត្រព្រះ ។

ដានី ៖ ឃុំព្រះនេត្រព្រះ ចឹងស្រុកព្រះនេត្រព្រះដែរ?

ណេង ៖ ចាំ! ស្រុកព្រះនេត្រព្រះ ។

ដានី ៖ ខេត្ត?

ណេង ៖ ខេត្តបន្ទាយមាជ័យ ។

ដានី ៖ ចុះប្តីមីងគាត់ឈ្មោះអីដែរ?

ណេង ៖ ឈ្មោះជាតិ ធួ ។

ដានី ៖ គាត់អាយុប៉ុន្មានហើយ?

ណេង ៖ អាយុ៥១ ។

ដានី ៖ ចុះមីងមានកូនចៅប៉ុន្មាននាក់ដែរ?

ណេង ៖ ខ្ញុំ៦ ទាល់តែគេបានកូនបានប្តីបានប្រពន្ធ សព្វថ្ងៃចិញ្ចឹមចៅមួយ ។

ដានី ៖ កូន៦នាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ណេង ៖ ប្រុស២ ស្រី៤ ដល់គេបានប្តីបានប្រពន្ធនៅលីវក៏រៀន មីនេះមួយ មីតូចនេះមួយ ។

ដានី ៖ ប្រុស២ ស្រី៤?

ណេង ៖ ចា៎!

ដានី ៖ បានរៀបប៉ុន្មាននាក់ហើយ?

ណេង ៖ បាន៤ហើយ ។

ដានី ៖ បាន៤ នៅសល់តែ២?

ណេង ៖ ចា៎!

ដានី ៖ ឪពុកមីងគាត់ឈ្មោះអីដែរ?

ណេង ៖ ឪពុកណា ឪពុកខ្ញុំ ។

ដានី ៖ បាទ! ឪពុកបង្កើត?

ណេង ៖ ឈ្មោះ ទិត ម៉ៅ ។

ដានី ៖ ឪពុកឈ្មោះ ទិត ម៉ៅ?

ណេង ៖ ចា៎! ម៉ែខ្ញុំឈ្មោះ រស់ គោម ។

ដានី ៖ ម្តាយឈ្មោះ រស់ គោម?

ណេង ៖ ចា៎!

ដានី ៖ គាត់នៅរស់ ឬក៏ស្លាប់?

ណេង ៖ នេះ ម៉ែខ្ញុំផ្ទះនេះ ។

ដានី ៖ គាត់នៅនឹង?

ណេង ៖ ម៉ែងាប់ហើយ ។

ដានី ៖ ចុះឪពុក?

ណេង ៖ ឪពុកស្លាប់តាំងពីជំនាន់ស្ដេទេ ស្លាប់អស់ហើយ ។

ដានី ៖ ចុះបងប្អូនបង្កើតប៉ុន្មាននាក់ដែរ?

ណេង ៖ បងប្អូនបង្កើត ប្រុស២ ស្រី៤ ។

ដានី ៖ ចុះមីងកូនទីប៉ុន្មានដែរ?

ណេង ៖ ខ្ញុំកូនទី មើល១ ២ ៣ ៤ ខ្ញុំកូនទី៤ ។

ដានី ៖ ចុះមីងកាលពីក្មេងៗបានរៀនសូត្រអីដែរ?

ណេង ៖ អត់ទេ កូន ។

ដានី ៖ កាលនៅតូចអត់បានចូលសាលារៀនទេ?

ណេង ៖ ទេ កាលរៀនថ្នាក់ទី១០ ខ្មោចពុកស្លាប់នៅកំពង់ស្ពឺខ្ញុំឈប់ ខ្មោចពុកខ្ញុំធ្វើទាហាន នេះខ្ញុំនិយាយឲ្យអស់ ។ ដល់ធ្វើទាហាន ម៉ែខ្ញុំបើកប្រាក់អំណោយបានមកផ្ទះវិញ ក៏ខ្ញុំឈប់ដើរបេះ ត្រកួនលក់ ។

ដានី ៖ ចឹងកាលនឹង កាលឪពុកមីងគាត់ធ្វើទាហាននៅកំពង់ស្ពឺ គ្រួសារទៅជាមួយគ្នាទាំងអស់?

ណេង ៖ ទៅ ទាំងខ្ញុំទាំងអី ។

ដានី ៖ ទៅនៅកំពង់ស្ពឺ?

ណេង ៖ ចាំ!

ដានី ៖ ហើយរៀននៅកំពង់ស្ពឺ?

ណេង ៖ អត់បានរៀនទេ ខ្ញុំរៀន ក៏មិនដឹងរៀន ខ្មោចពុកទៅនៅនោះជាងម៉ាឆ្នាំក៏មិនបានរៀន ខ្ញុំនេះដល់ពុកស្លាប់ គេឲ្យមកវិញបើកប្រាក់អំណោយបាន២៥ម៉ឺនរួចមកវិញ នឹងខ្ញុំកត់ឲ្យអស់ ចង់និយាយ ។

ដានី ៖ មកវិញ អត់បានចូលសាលា?

ណេង ៖ អត់ទេ កូនក្រណាស់ពេក ចិញ្ចឹមប្អូនក្រោយៗ ។

ដានី ៖ ចុះចេះអាន ចេះសរសេរ?

ណេង ៖ ចេះៗបើអ្នកណានិយាយអីចេះ ។

ដានី ៖ និយាយអានសៀវភៅអក្សរអីអានដាច់?

ណេង ៖ អត់ ពីដើមមិញខ្ញុំធ្វើប្រធានប៉ោយសំរោង ដល់បានប្ដីប្រពន្ធ កូនច្រើនក៏ភ្លេចអស់ៗហើយខ្ញុំមិនចេះទេ ឆ្លើយថាមិនចេះស្រួល ។

ដានី ៖ ចុះមីងរាល់ថ្ងៃនឹងធ្វើអីទៅ?

ណេង ៖ គ្មានធ្វើអីទេ សព្វថ្ងៃនោះចិញ្ចឹមគោមួយ ។

ដានី ៖ អត់មានរបររកស៊ីធ្វើអី?

ណេង ៖ មិនមានអីទេ ដីងទៅលក់ទិញដូរអីទេ ។

ដានី ៖ ប៉ុននៅពាល់ថ្ងៃនឹង អត់មានធ្វើការងារ?

ណេង ៖ ចិញ្ចឹមគោ គ្រាន់គេឲ្យមួយខែ១០០០ ២០០០ ក៏បានចាយ ។

ដានី ៖ នៅផ្ទះមើលគោ?

ណេង ៖ ចាំ! នៅផ្ទះមើលគោ ។

ដានី ៖ កូនឲ្យលុយមក?

ណេង ៖ មក ។

ដានី ៖ កូនធ្វើការនៅណា?

ណេង ៖ នៅថៃ ក្រណាស់ពិត បើទៅមើលផ្ទះខ្ញុំចុះ ខ្ញុំបានអ្នកណាសម្លាសន៍ចង់ឲ្យទៅមើលផ្ទះខ្ញុំក្រណាស់ កូនអើយ ។

ដានី ៖ ចឹងមីងកាលនឹងអត់បានរៀនសូត្រ ចឹងធ្វើអីទៅ?

ណេង ៖ អត់ ។

ដានី ៖ ចុះនៅផ្ទះធ្វើអីទៅ នៅជាមួយឪពុកម្ដាយ?

ណេង ៖ នៅផ្ទះក៏ខ្ញុំក៏ដើរបេះត្រកួន បេះអីចិញ្ចឹមប្អូនក្រោយៗ ។

ដានី ៖ ជួយធ្វើការងារឪពុកម្ដាយ?

ណេង ៖ ទេ! ពុកងាប់កំពង់ស្ពឺចុះ ដល់ចេះបើម៉ែរកអីមិនបានក៏ខ្ញុំបេះត្រកួន បិទស្រា បិទអីលក់ទៅណា កាលនោះយើងមានម៉ាស៊ីនពីណា ។

ដានី ៖ ជួយធ្វើការងារម្ដាយ?

ណេង ៖ ចាំ!

ដានី ៖ នៅជាមួយម្ដាយរហូតដល់ពេលណា?

ណេង ៖ ទាល់តែបានប្ដី ដឹងប៉ុន្មានទេ ៧៩ដឹងទេ ដែលយួនចូលរួច ភ្លេចអស់អានោះខ្ញុំភ្លេច ។

ដានី ៖ ចុះពេលប៉ុលពតចូល?

ណេង ៖ ប៉ុលពតចូល យើងទៅនៅនោះ យើងនៅស្រែះ ។

ដានី ៖ កាលប៉ុល ពតចូល កាលនោះមីងនៅជាមួយម្ដាយ?

ណេង ៖ នៅជាមួយម្ដាយ ពុកអត់មានទេ ពុកងាប់ទៅ ។

ដានី ៖ ចឹងពេលដែលប៉ុលពតចូល បាយរួមបាយអីនឹង នៅជាមួយឪពុកម្ដាយនៅឡើយទេ?

ណេង ៖ ចាំ! ដល់ពេលគេចល័តនេះ ឲ្យខ្ញុំទៅត្រពាំងថ្ម ។

ដានី ៖ ចុះមីងនៅជាមួយម្ដាយរហូតដល់ពេលណា?

ណេង ៖ ដឹងជាឆ្នាំប៉ុន្មានកូន ដល់វាក្មេងអស់អត់ដឹងស្គាល់ ចាំមើលណា ពុកងាប់នៅកំពង់ស្ពឺរួចខ្ញុំមក ដល់ប៉ុលពតនេះ គេបញ្ជូនខ្ញុំទៅត្រពាំងថ្ម ។

ដានី ៖ ឆ្នាំណា បានជូនមីងទៅត្រពាំងថ្ម?

ណេង ៖ មិនដឹងក្មេងអានេះ មិនដឹងទេ ។

ដានី ៖ ចាំមើលឆ្នាំ៧៥ ៗ ប៉ុកពតគេឈ្នះលន់ នល់ ហើយទៅគេ?

ណេង ៖ មិនដឹងទេ មិនបានជាគិតទេ គេចេះតែប្រើ ចេះតែទៅ ។

ដានី ៖ ចឹងពេលដែលប៉ុលពត ចូលមកដំបូង កាលនឹងគេឲ្យមីងធ្វើអី?

ណេង ៖ ខ្ញុំនោះគេប្រើស្ទូង ដកជាមួយយាយៗតាៗ ខ្ញុំចេះតែទៅ ។

ដានី ៖ កាលនោះអត់ទាន់នៅកងចល័តអីទេ នៅ?

ណេង ៖ ទេ! ដល់ចល័តណាកូន បានចេញទៅនៅត្រពាំងថ្ម ហើយរែកដី រែកឡើង ខ្ញុំនិយាយអស់ ។

ដានី ៖ កាលដំបូងកាលមីងនៅដកស្ទូងជាមួយយាយៗ តាៗ ដកស្ទូងនៅណា?

ណេង ៖ ដកស្ទូងប៉ុស្តិ៍២ ។

ដានី ៖ នៅប៉ុស្តិ៍២?

ណេង ៖ ប៉ុស្តិ៍២យើង ។

ដានី ៖ ម៉េចបានមីងទៅធ្វើជាមួយយាយៗតាៗ?

ណេង ៖ គេរើស ពីដើមមិញខ្ញុំតូច ដល់គេរៀងទ្រើស គេប្រែទៅគេយកយើងទៅនោះ យកទៅ ត្រពាំងថ្ម អានេះកុមារ អានោះតូច ។

ដានី ៖ អត់ទេ ខ្ញុំចង់ដឹងមីងដូចថាពេលដែលប៉ុលពតចូលមកដំបូងនឹង កាលនឹងគេដកស្ទូងជាមួយ យាយៗតាៗ?

ណេង ៖ ទេ! ចល័តយើងដើរកាប់កន្ទ្រានទ្រុងទៅឲ្យតែគេឲ្យបាយស៊ី ។

ដានី ៖ កាលនោះគេឲ្យយើងចូល យើងចូលម៉េចមីង?

ណេង ៖ ទេ! ដឹងនារីនោះគេរើសយកចូល ។

ដានី ៖ គេរើសចូល គេហៅអីគេ?

ណោង ៖ គេហៅអាយុ១៦គេរើស បែកពីម៉ែ ខ្ញុំទៅចោលម៉ែៗនេះ វែកដី វែកយប់ អ្នកខ្វាក់មាន់ដឹកគ្នានោះ សួរខ្ញុំទៅ ខ្ញុំសម្លាសន៍ឲ្យអស់ ។

ដានី ៖ ពេលដំបូងពី៧៥មក មីងអត់ដឹងថា?

ណោង ៖ មិនដឹងជា៧០ប៉ុន្មាននោះ អត់គិតកូន មិនគិតទេ ។

ដានី ៖ ពេលដែលប៉ុលពតចូលមកនៅភូមិយើងដំបូង?

ណោង ៖ អត់គិត គេជម្លៀសទៅណាចេះតែទៅ ម៉ែខ្ញុំផ្ទះនេះគេឲ្យទៅនៅនោះ នៅភូមិកណ្ដាល ។

ដានី ៖ ចុះមីងនៅណា?

ណោង ៖ ខ្ញុំចល័តគេបញ្ជូលទៅតាមគេ ។

ដានី ៖ ទៅណា?

ណោង ៖ ពីដើមមិញខ្ញុំនៅចំការកប្បាសនៅភ្នំបាក់យើង កងវ៉ា បកពីនោះមកគេឲ្យខ្ញុំទៅជីកអាងត្រពាំង ថ្ម ។

ដានី ៖ ចឹងកាលនឹងមីងទៅនៅចំការកប្បាស?

ណោង ៖ ចំការកប្បាស យើងអាយុប៉ុន្មានមិនដឹងទេ ។

ដានី ៖ មុនដំបូងបំផុតគេបកឲ្យទៅនៅចំការកប្បាស?

ណោង ៖ ចំការកប្បាស បកចំការកប្បាស ។

ដានី ៖ កងចល័តចូលហៅអី?

ណោង ៖ យើងចល័តប៉ុលេង ឲ្យតែពេញវ័យយកទៅទាំងអស់ ។

ដានី ៖ ប៉ុនគេហៅកងអី?

ណោង ៖ កងចល័តប៉ុលេង ស្គាល់ទាំងប្រធានទៀត ។

ដានី ៖ កងចល័តប៉ុឡេង?

ណោង ៖ ប៉ុឡេងនេះ ប្រធានធំ និរតី ។

ដានី ៖ ពេទ្យឡេង ឬ ប៉ុឡេង?

ណោង ៖ ប៉ុឡេង ។

ដានី ៖ ចាំមើលកាលដំបូងមក ក្រែងឆ្នាំ៧៥មក ពួកនិរតីអត់ទាន់មកនៅ?

ណោង ៖ នោះយើងមិនដឹងអ្នកមក មិនដឹងស្រុកស្រែគេអ្នកណាគេចេះតែប្រើ ។

ដានី ៖ ប៉ុន្តែដំបូង?

ណោង ៖ ដំបូងយើងនៅភ្នំបាក់កងវ៉ា ។ បន្ទាយឆ្មារ បកមកវិញបាននៅភ្នំបាក់ ។

ដានី : ដំបូងគេបញ្ជូនមីងទៅបន្ទាយឆ្មារ?

ណោង : ចា៎! ឲ្យទៅច្រូតស្រូវ

ដានី : ច្រូតស្រូវ គ្នាច្រើនកាលនឹង?

ណោង : អឺ! គ្នាច្រើនណាស់រាប់រយនាក់ អត់បានរាប់ បើគេសួរចេះយើងរកមិនត្រូវ ដឹងយើងនៅចាំចេះ ។

ដានី : អត់ដឹងថាទៅប៉ុន្មានខែ?

ណោង : អត់ដឹងទេ នៅប្រហែលជាងម៉ាខែកន្លះនៅកងវ៉ា កាប់គាស់គល់ ថានិយាយប្រវត្តិបើអង្គការមកសម្ភាសន៍ចេះ ។

ដានី : គាស់គល់ដល់ពេលណា?

ណោង : គាស់គល់នោះ ចាំមើលណាកូន ១៥គល់ គេឲ្យសម្រាកម៉ាថ្ងៃ បើយើងឈប់ទៅ ស្អែកឡើងគាស់ទៀត ។ ខ្ញុំហែលអស់ហើយ មកសម្ភាសន៍ចេះ ខ្ញុំចង់ណាស់ ។

ដានី : ចុះគាស់ដល់ពេលណាទៅបានគេបញ្ជូនមីងទៅអាងត្រពាំងថ្ម?

ណោង : នែក! ដល់វាជីកអាងចេះមិនចេះរួច គេស្នើពួកខ្ញុំចំការកប្បាសនេះឲ្យទៅជួយជីកអាង ។ ដល់ ជីកអាង អ្នកខ្វាក់មាន់ ជីកគ្នាឡើងទំនប់ វាថាយើងធ្វើពុត ។ សម្ភាសន៍ចុះកូន ចាំខ្ញុំនិយាយ ឲ្យស្តាប់ ។

ដានី : ចឹងដំបូងគេបញ្ជូនមីងទៅលើកប៉ុន្មាន?

ណោង : ទៅប៉ុន្មានថ្ងៃនោះ៨នាក់ ថ្ងៃដកពីចំការកប្បាសទៅ ។

ដានី : ទៅ៨នាក់ មីងចាំពីណាខ្លះ៨នាក់?

ណោង : មិនដឹងទេ ព្រោះនៅទឹកជោរ អ្នកភ្នំពេញគេមកជង ខ្ញុំនេះទិត មុន, និង ទិត ណោងនេះទៅ ទាំងបងទាំងប្អូន ឲ្យតែគេឲ្យទៅ ។

ដានី : ចំការកប្បាសនៅណា?

ណោង : ចំការកប្បាស កងវ៉ៃយើងភ្នំបាក់នៅនឹងបៀតស្វាយ ខ្ញុំស្គាល់ចំការខ្មុរក៏ខ្ញុំស្គាល់ គេឲ្យកាប់គាស់ហើយ កម្មណាស់ ។

ដានី : ចំការកប្បាសនៅភ្នំបាក់?

ណោង : ចា៎!

ដានី : ភ្នំបាក់ ហើយភ្នំបាត?

ណោង : ភ្នំបាក់ៗយើង ដាំលើភ្នំទាំងអស់ ។

ដានី ៖ នៅឃ្យូរទេ នៅចំការកប្បាស?

ណោង ៖ ឃ្លួនចូល ដែលឃ្លួនកំពុងវល់វេក(ប្រូបូកប្រូបល់) នេះ ខ្ញុំរស់មកនៅសាលាក្រៅ ។

ដានី ៖ មីងមិញមីងមានប្រសាសន៍ថា មុនបញ្ជូនទៅធ្វើនៅត្រពាំងថ្ម ក្រែងធ្វើនៅចំការកប្បាស?

ណោង ៖ ចំការកប្បាសៗ គេប្រែក៏ដូចខ្ញុំចេះ បងនាំគ្នាទៅ ខ្ញុំគេដឹកឡាន ។

ដានី ៖ មីងគេដកទៅអាងត្រពាំងថ្ម?

ណោង ៖ ចាំ!

ដានី ៖ អាងត្រពាំងថ្ម ដកគ្នាទៅ៨នាក់?

ណោង ៖ ទៅ៨ទឹកជោរផង ពួកដល្បី យើងដែលស្គាល់ណា អានេះយើងចាំ យើងនិយាយបាន ។

ដានី ៖ កាលនឹងមីងផ្លាស់ទៅ អាងត្រពាំងនឹង ពីណាគេអ្នកមកប្រាប់ មកដឹកយកទៅ?

ណោង ៖ មុី(មេ)គេមកយក បើមុី(មេ)នេះ បងម៉េងនេះ ងាប់ហើយ ដឹងនិយាយកើត និរតីងាប់ហើយ ។ ចេះកូនណាំកូន ជំនាន់កូនកើតក្រោយទេ ។

ដានី ៖ ចឹងកាលនឹងពេលមាននិរតីមកហើយ បានគេដកមីងឲ្យទៅធ្វើត្រពាំងថ្ម?

ណោង ៖ ទេ! កូនដល់កប្បាសរួច បានគេដកទៅវែកដីនិរតី ខែ៥-៦ពេញបាញ់ថ្នាំ ដល់រួចបេះកប្បាសនេះ ក៏គេយកយើងទៅវែកដី ។

ដានី ៖ ទៅវែកដី មីងវែកនៅម្តុំណា នៅត្រពាំងថ្ម?

ណោង ៖ ខ្ញុំវែកបៀតដើមពោធិ៍ធំ ។

ដានី ៖ ដើមពោធិ៍ធំនៅកន្លែងណា?

ណោង ៖ ដើមពោធិ៍ធំបៀតស្ពានធំ ទៅខាងកើតចេះ ។ សព្វថ្ងៃមិនដែលឃើញ ពីដើមមិញវាឲ្យដាំដើមពោធិ៍ប្រហែលប៉ុននេះ នេះខ្ញុំចាំទាំងអស់ ប៉ុននេះគេធ្វើជារៀងចេះ អាស្ពាននៅខាងលិចដើម ពោធិ៍ ។

ដានី ៖ កាលនឹងគេវែកយ៉ាងម៉េចទៅ ក្នុងម៉ាថ្ងៃប៉ុន្មានប៉ុន្មានម៉ែត្រ?

ណោង ៖ អត់មានទេ ដល់ពេលស៊ីបាយស៊ីរួច ចាប់វែកទៀតដល់ម៉ោង៩បានឈប់ ។

ដានី ៖ ចឹងចូលធ្វើការពេលព្រឹកព្រលឹមឡើងចាប់ពីម៉ោងប៉ុន្មានចាប់ផ្តើម?

ណោង ៖ ដូចជាមិនមាន យើងកាលនោះមិនមានទេ ឲ្យតែគេស៊ីផ្អែតចេះតែខំវែក ។

ដានី ៖ អត់ទេ ខ្ញុំចង់ដឹងថាពេលព្រលឹមឡើង ដូចថាយើងទៅដល់កន្លែងត្រពាំងថ្មនឹង ព្រលឹមឡើងម៉ោងប៉ុន្មាន យើងចាប់ផ្តើមវែក?

ណោង ៖ មិនបានរាប់ម៉ោងផង ។

ដានី ៖ មីងស្មានមើល?

ណេង ៖ មិនបានរាប់ទេ ។ ដូចថានេះដងវែកហើយបង្កឺវែកឲ្យចាំ អានេះរបស់អីផ្សេង យើងចេះតែវែក ដល់ម៉ោងស៊ីបាយ ដល់ស៊ីរួចនេះ ។

ដានី ៖ ចឹងមុនចូលវែកគេឲ្យយើងស៊ីបាយសិន?

ណេង ៖ ទេ! ព្រឹកអត់មានទេ ។

ដានី ៖ អត់មានទេ?

ណេង ៖ អត់មានទេ ខ្ញុំថាបើសម្អាសន៍ៗដល់ទៅត្រពាំងថ្មទៀត ឈរសម្អាសន៍នឹងដើមពោធិ៍ ។

ដានី ៖ ចុះមីងចូលម៉ោងប៉ុន្មានបានគេឲ្យហូបបាយពេលថ្ងៃ?

ណេង ៖ ម៉ោង ប៉ះណាម៉ោង១១ ប៉ះណា១១កន្លះគេឲ្យស៊ី ដល់ស៊ីៗមិនដែលឆ្អែតដែរកូន បបរចែកគ្នា បបរបើអ្នកណាមិនធ្វើការអត់ហើយកូន ។ កូនឯងនេះក្រោយទេ ។

ដានី ៖ ចឹងមីងបន្ទាប់ពី ចាំមើលយើងហូបបាយម៉ោង១១ៗកន្លះ ម៉ោងប៉ុន្មានបានចូលធ្វើការទៀត?

ណេង ៖ ដឹងម៉ោងប៉ុន្មានទេ ឲ្យតែប្រធានហៅដឹងថាចូល ។

ដានី ៖ ម៉ោងប៉ុន្មានចាប់ផ្ដើម?

ណេង ៖ ដឹងម៉ោងប៉ុន្មាន កាលយើង គេមិនដែលកំណត់ទេ ឲ្យតែគេហៅឲ្យលឿនគេទៅតាម ។

ដានី ៖ ចុះអត់មានដាក់ផែនការអី យើងត្រូវលើកប៉ុន្មានម៉ែត្រៗក្នុងម៉ាថ្ងៃ?

ណេង ៖ ម៉ែត្រគីប ។

ដានី ៖ ម៉ែត្រគីបប៉ុន្មាន?

ណេង ៖ ម៉ែត្រគីប ការនេះបើសិនណារួចនេះគេឲ្យយើងឈប់ យើងធ្វើមិនរួចដែលយើងស្គម ។

ដានី ៖ ចុះមីងគេឲ្យវែកប៉ុន្មានម៉ែត្រគីបក្នុងម៉ាថ្ងៃ?

ណេង ៖ វែកប្រហែលកំពស់ស្មើផ្ទះនោះ កូនវែកឡើង បើអ្នកខ្វាក់មាន់នេះដឹកដៃគ្នាឡើង ។

ដានី ៖ ខ្ញុំចង់ដឹងថាម៉ាថ្ងៃគេឲ្យយើងវែកប៉ុន្មានម៉ែត្រគីប?

ណេង ៖ ទេ! អានេះកាប់ធូរ កូនឯងចង់កាប់ៗដាក់ វែកខ្ញុំចេះវែក គេថាទៅខ្វាចគេថាមកដូចប្រធាននាង‌នេះឈរចេះថាយើងណា ។ ដូចនាងនេះ ឈរថា ឆាប់វែកទៅប្រធានគេមក ។

ដានី ៖ ប៉ុន្តែយើងធ្វើយើងហើយប៉ុន្មាន បានគេឲ្យយើងឈប់?

ណេង ៖ កាលនោះអត់បានកំណត់ទេ គេស្គមដាច់អស់ហើយ អាច់ពោះយើងវែកទៅមិនរួច ។

ដានី ៖ ប៉ុន្តែមីងអត់ដឹងថា គេឲ្យវែកប៉ុន្មានអីប៉ុន្មាន?

ណោង ៖ ឯងនោះផ្សេង បើពួកខ្ញុំសួរដូចអត្តុយ បើអត្តុយឃើញប្រធានគេមកចេះៗក៏យើងក្រោកទៅទៀតណា៎ ខ្លាចគេ ។ ប៉ុនដើមពោធិ៍នោះធំហើយ ដើមពោធិ៍បៀតស្ពាន ដើមពោធិ៍ដាក់កាលបដិវត្ត ។

ដានី ៖ ប៉ុនណា?

ណោង ៖ កាលដាំប៉ុននេះ ចិនប្រទេសចិនមកស្តីសៀកចិនគុយ មកខ្ញុំឈរទទួលនេះឯង ។

ដានី ៖ ឈរទទួលមកនៅណា?

ណោង ៖ មកសម្ភាសន៍នឹងដើមពោធិ៍នោះ នឹងអាត្រពាំងថ្ម គេថាធ្វើដៃធ្វើជើងថា អឺ!ខ្មែរឲ្យតែហូបបាយអស់ទាំងឆ្នាំងៗធ្វើអីក៏កើតដែរ អានោះខ្ញុំសម្ភាសន៍ហើយ ។

ដានី ៖ សម្ភាសន៍ម៉េច?

ណោង ៖ សម្ភាសន៍នោះគេឲ្យឈរទទួលគេ សៀកចិនគុយ គេមកពីប្រទេសចិន ។

ដានី ៖ ពីណាឈ្មោះអី?

ណោង ៖ សៀកចិនគុយ ។

ដានី ៖ សៀកអ៊ីងគុយ?

ណោង ៖ សៀកចិនគុយចេះស ប្រទេសចិនដែលគេមក ។

ដានី ៖ គេប្រាប់ថាម៉េច?

ណោង ៖ គេថាខ្មែរណា ល្អណាស់ធ្វើទន្លេសមុទ្រក៏បានដែរ ឲ្យតែមានបាយហូបទាំងឆ្នាំងៗ វានិយាយចេះ ពួកយើងឈរដង្ហែរគ្នាពីមាត់នេះមក ។

ដានី ៖ កាលនោះមីងបានទទួលគេមក?

ណោង ៖ ទទួល កាលទឹកមក ទឹកអាង ។

ដានី ៖ ឆ្នាំណាគេមក?

ណោង ៖ អូ! យូរហើយកូន ភ្លេចអស់ហើយខ្ញុំ ។

ដានី ៖ ចុះមីងធ្វើការនៅគ្នាប៉ុន្មាននាក់ម៉ាក្រុមរបស់មីង?

ណោង ៖ អឺ! ភ្លេចអស់ហើយ ២០-៣០ឆ្នាំដឹង យើងបដិវត្ត ។

ដានី ៖ កាលនឹងយើងហូបតែបបរទេ?

ណោង ៖ បបរៗកូន ។

ដានី ៖ ហូបឆ្អែត?

ណេង ៖ មិនបានឆ្អែតទេ ចេះតែទៅ ។ បាយខ្វះសួរទៅវាំនេះនៅខាងនេះទេ គេឲ្យស៊ីបាយក៏យើងមានកម្លាំង ។ ថាអានាងអើយ ខ្ញុំប្រាប់ថាឲ្យសម្ភាសន៍ចាំខ្ញុំសម្ភាសន៍ ឈរសម្ភាសន៍ឥឡូវនិយាយឲ្យល្អ ។

ដានី ៖ ចុះមីងបន្ទាប់ពីដូចថាយើងវែកដីវែកអីហើយ គេឲ្យធ្វើអីទៀត?

ណេង ៖ គ្មានធ្វើអី ដេក ។

ដានី ៖ ចុះប្រធានគេឈ្មោះអី អ្នកគ្រប់គ្រង?

ណេង ៖ មិនស្គាល់សុទ្ធតែអ្នកថ្មីមកកាន់កាប់ និរតីទាំងអស់មកកាន់កាប់ ។

ដានី ៖ ស្គាល់ឈ្មោះនិរតី?

ណេង ៖ មិនស្គាល់ ភ្លេចអស់ ងាប់អស់ហើយ ។

ដានី ៖ អ្នកធំជាងគេឈ្មោះអី?

ណេង ៖ មិនស្គាល់ ឃើញតែគេប្រើយើងចេះតែទៅ ដឹកដៃគ្នាឡើងទំនប់ ខ្ញុំហើយហែលហើយ ។

ដានី ៖ ចុះមីងមានប្រសាសន៍ដឹកដៃគ្នាឡើងទំនប់ ងងឹតមាន់គេឲ្យលើកពេលយប់ទៀត?

ណេង ៖ យប់ ។

ដានី ៖ យប់ម៉ោងប៉ុន្មាន?

ណេង ៖ យប់ម៉ោង១០ឲ្យឈប់ ។

ដានី ៖ ម៉ោង១០ឲ្យឈប់?

ណេង ៖ ចាំ! បើអ្នកណាងងឹត ទៅ ។

ដានី ៖ ម៉េចបានងងឹតមាន់?

ណេង ៖ មិនដឹងងងឹតម៉េច បើចាក់ហើយវាមិនដឹង ។

ដានី ៖ បាទ?

ណេង ៖ បើចាក់ភ្នែកហើយវាមិនដឹង គ្នាចេះងងឹតបណ្ដោយតាមអ្នកភ្លឺគេដឹកដៃត្រឹមម៉ោងគេឲ្យយើងដេក ។

ដានី ៖ ចុះមីងងងឹតមាន់ដែរអត់?

ណេង ៖ ទេ!

ដានី ៖ អ្នកដែលវែកជាមួយមីងងងឹតមាន់?

ណេង ៖ អ្នកថ្មីៗ ។

ដានី ៖ អ្នកថ្មី?

ណោង ៖  អ្នកថ្មី អ្នកភ្នំពេញអ្នកអីណា ។

ដានី ៖  អ្នកភ្នំពេញ?

ណោង ៖  ចា៎! ដែលគ្នាឈឺគ្នាអី ។

ដានី ៖  ចឹងមានអ្នកភ្នំពេញលើកជាមួយមីងដែរ?

ណោង ៖  មានៗក៏យើងមិនស្គាល់ទេ សព្វថ្ងៃគេទៅធ្វើបុណ្យខ្លះទៅយើងមិនស្គាល់គេ ។ ខ្ញុំថាបើត្រពាំងថ្ម ខ្ញុំជិតហើយ ខ្ញុំប្រាប់ចេះឯង ។

ដានី ៖  ចុះមីងហូបបបរជាមួយស្អីទៅ?

ណោង ៖  ហូបបបរត្រីប្រារៀងពីដើមមិញ អាត្រីស្អុយក៏គេចំហ៊ុយម៉ាចានអាចានប្រហែល២កន្ទុយ គេដាក់ទៅ៤-១០នាក់ក៏ស៊ីទៅ អស់ក៏អត់ទៅ ។

ដានី ៖  អានឹងរាល់ថ្ងៃ ក៏មានម្ហូបអីផ្សេង?

ណោង ៖  មានខ្លះ ស្ងោរៗត្រកួនស្ងោរអីចេះឲ្យស៊ី ។

ដានី ៖  ស្ងោរត្រកួន?

ណោង ៖  ចា៎!

ដានី ៖  ហើយស្អីទៀត មានត្រី មានសាច់អីដែរអត់?

ណោង ៖  មាន គេឲ្យស៊ីនោះឯង ។

ដានី ៖  ត្រីគេ មាន?

ណោង ៖  កូនអើយប៉ះណា ត្រីគេយកពីណាពីណែចេះតែឲ្យស៊ីៗ ឲ្យចេះតែរស់ ខ្ញុំហែលអស់ហើយកូន បើឲ្យអ្នកណាសម្ភាសន៍ៗនិយាយទាំងអស់ដូចខ្ញុំសេចក្តីខ្ញុំស្គាល់ ស៊ីមិនឆ្អែតហើយ និយាយពីអន្ទុយអស់កម្លាំង គេថាហ៎!ទៅទៀតទៅ ខ្លាចគេវ៉ៃ ។

ដានី ៖  ចុះមីងកន្លែងគេជីកដី ហើយនឹងលើកឡើងចាក់លើទំនប់នឹង ចំងាយណាទៅ?

ណោង ៖  ខ្ពស់ណាស់កូន ប្រហែល៣ម៉ែត្រ វាចេះតែឲ្យឡើងៗ យើងចេះតែឡើងទៅវាឈោងវាដើរ ។

ដានី ៖  ចុះមីងអ្នកកាប់ដី ហើយអ្នករែក?

ណោង ៖  ខ្ញុំរែក ប្រុសៗអ្នកកាប់ ។

ដានី ៖  ប្រុសៗអ្នកកាប់?

ណោង ៖  កាប់ ។

ដានី ៖  គ្នាប៉ុន្មាននាក់កាប់?

ណោង ៖ ច្រើនណាស់កូន ថែវប្រហែលពីនោះទៅឆ្ងាយសាលាឆទាន ។

ដានី ៖ ឆ្ងាយ?

ណោង ៖ ចា៎! ថែវ កើតអាងត្រពាំងថ្ម ។

ដានី ៖ ចុះអ្នកលើក អ្នកវែកដី?

ណោង ៖ អ្នកលើកដូចអានាងឯងក្រុមនាងឯងប៉ុន្មាន២០នាក់ អានាងឯងដើរមើលចេះអ្នកណាមិនវែក ក៏ថាទៅ ឆាប់មុំធំមួយវែកទៅទៀតហើយ អាណាងនឹតក៏គោងអញមក កូនអើយកម្មណាស់ សួរមីងទៅ ។

ដានី ៖ យើងហូបតែបបរទេ?

ណោង ៖ ទេ! ថ្ងៃណាគេឲ្យបាយស៊ីៗ ថ្ងៃណាដូចត្រីប្រាយើងវាក្រហមអស់ហើយកូនស្ងោរបានដាក់ម្ជូរ ហូត ដល់ស៊ីរួចយើងអង្គុយមុជទឹករួចគេថាវែក ។

ដានី ៖ មានទឹកមុជដែរ?

ណោង ៖ មានៗ ។

ដានី ៖ ទឹកមកពីណា?

ណោង ៖ មានខាងត្បូងអាង ។

ដានី ៖ ត្បូងអាង?

ណោង ៖ ចា៎!

ដានី ៖ ចុះមីងដែលធ្លាប់មកលេងផ្ទះទេ?

ណោង ៖ មិនដែលឲ្យមកទេ ម៉ែខ្ញុំក្រុបសំពត់ស គេមិនដែលមក អានេះផ្ទះម៉ែខ្ញុំខាងនោះផ្ទះនេះ ខ្ញុំចល័តពីដើមមិញ ។

ដានី ៖ ចុះម្តាយមីងគាត់ទើបសម្លាប់ជិនាន់ប៉ុលពត?

ណោង ៖ ទេ! ម៉ែទើបនឹងស្លាប់ កាលម៉ែក្រុបសំពត់ស ខ្ញុំនៅចំការកប្បាស នៅបៀតព្រហូតយើង ។

ដានី ៖ ចឹងគាត់ឈឺ?

ណោង ៖ ឈឺៗ ខ្ញុំសុំគេមក គេមិនឲ្យមកទេ ដល់យូលតើ បានខ្ញុំបានមកផ្ទះ ។

ដានី ៖ ចុះមីងក្រុបសំពត់ស មានន័យថាម៉េច?

ណោង ៖ ថាម៉ែឈឺទៅពេទ្យ ពីដើមមិញថាទេ បើអ្នកណាទៅផ្តាំថាម៉ែឈឺហើយសុំគេមិនឲ្យមកក៏មីងនេះ នៅនឹងព្រហូតៗ យើងនៅបៀតស្វាយ គេមិនឲ្យមក ក៏ខ្ញុំមិនមកៗ គេមិនឲ្យមកយើងមាន

សំបុត្រស្នាមពីណាមក ត្រង់នេះផាប់អស់ហើយ មានតែខ្ញុំទេ ខ្ញុំចាំ ខ្ញុំប្រាប់ខ្ញុំហែលអស់ហើយ ម៉ាដាន់នេះ ។

ដានី : ចុះមីងអ្នកដែលធ្វើការនៅកងមីងមានគេយកទៅសម្លាប់ យកអីអត់?

ណោង : មានអ្នកសុទ្ធតែអ្នកល្អ យើងកូនអ្នកទឹកដោរ ។

ដានី : មានគេចាប់មានអី?

ណោង : អត់ទេ យើងអ្នកចាស់បានអី វាចាប់តែអ្នកថ្មី ។

ដានី : ចាប់អ្នកថ្មី?

ណោង : ចា៎! ដែលស្គមតែលគោលធ្វើការមិនកើត ។

ដានី : គេចាប់យកទៅណា?

ណោង : ដឹងចាប់យកទៅណា វាមិនឃើញ ។

ដានី : អត់ឃើញ?

ណោង : ដូចចាប់ឈ្មោះកូនឯង ក៏បាត់ អាមនុស្សក៏បាត់យើងចេះតែខំ កូនម៉ែខំណាស់ កុំអីអំបានទៅរស់ប៉ុននេះ វាប្រើនេះប្រើហួសនិស្ស័យហើយ ។ ខ្ញុំថាតែក!ត្រពាំងថ្មឲ្យខ្ញុំសម្អាសន៍ ខ្ញុំនិយាយដឹងទាំងអស់ ។

ដានី : ប៉ុន្តែមីង ចុះប្រធានត្រពាំងថ្មឈ្មោះអី?

ណោង : មិនស្គាល់ អត់បានស្គាល់ទេ ភ្លេចអស់ហើយ ។ ប្រធានផ្លាស់គ្នាឡើង កូនឯងមិនកើតផ្លាស់អ្នកផ្សេង ។

ដានី : ចុះដំបូងពីអ្នកណាគេ?

ណោង : មិនដឹងទេ ។

ដានី : ចុះបន្ទាប់?

ណោង : បន្ទាប់មិនដឹងទេ ដូចថាគេប្រើអំអើយអានេះមិត្តនារីខាងនេះ ចា៎! ។

ដានី : ហេតុអីបានគេលើកអាងត្រពាំងថ្ម មីងដឹង?

ណោង : មិនដឹង គេយកទៅចេះតែទៅ ។

ដានី : អាងត្រពាំងថ្មបណ្តោយប្រវែងប៉ុន្មាន?

ណោង : អត់បានស្គាល់ទេកូនអើយដាច់ទៅដើងឡើងស្លួច សុទ្ធតែលើកកូន មិនមានអាសេរីណាទេចូលទេ សួរទៅ ។

ដានី : ចុះទទឹង?

ណោង ៖ មិនស្គាល់ ។

ដានី ៖ កំពស់វា អត់ដឹង?

ណោង ៖ បើកំពស់វាឡើងទៅដូចចុះចំនោទ ឡើងបណ្ដាក់នឹងដី បើរឿងទៅត្បូងកូនខ្ញែងអីចេះទាំងអស់ យើងអត់ដឹងទេ ។ បក្សខាងខ្ញុំបៀតដើមពោធិ៍ទេ បៀតមុខទ្វារ ខ្ញុំស្គាល់ទាំងអស់ ខ្ញុំហែលហើយ ពួកគេថាមើលរស់ឡើង ។

ដានី ៖ ចុះមីង កាលជិតនាំនឹងដែលពួឈ្មោះយាយថែម?

ណោង ៖ យាយថែម កូនម៉ែអើយនិយាយពីកាច ។

ដានី ៖ គាត់កាចម៉េច?

ណោង ៖ គាត់កាចណាស់ យាយថែម និរតី កាចណាស់កូន ។

ដានី ៖ កាចម៉េច?

ណោង ៖ មនុស្សមិនសំងំ ត្រូវអួសភ្លាមវៃភ្លាម សួរខ្ញុំទៅ យាយថែមនៅ ។

ដានី ៖ យាយថែមអួសភ្លាម វៃភ្លាមម៉េច មីងអាចរៀបរាប់រឿងរ៉ាវនឹងបាន?

ណោង ៖ ដូចថាគ្នាអ្នកថ្មី គ្នាមិនតក់តើន អួសទៅមិនដឹងទៅណាទេ យាយថែមកាចអើយកាច យាយថែមគេថាមាឌតូច ខ្ញុំមិនដែលឃើញ មិនដែលមកដល់កន្លែងខ្ញុំទេ ។

ដានី ៖ អត់ដែលឃើញទេ?

ណោង ៖ អត់ទេ ។

ដានី ៖ ចុះម៉េចមីងដឹងថា គាត់កាច ហើយគាត់អួសអ្នកថ្មី?

ណោង ៖ ពួតែគេថា ។

ដានី ៖ ពួពីណាថា?

ណោង ៖ អាកាល់កងបដិវត្តដូចថាកងលិច បៀតស្ដី បៀតភូមិគេនោះភូមិទៅលិច គេថាយាយថែមមកហើយ ។ និយាយពីម្នាក់ៗខ្លាច ដឹងមុខតយាយថែមទៅណា ខ្ញុំមិនដែលឃើញទេ ។

ដានី ៖ អត់ដែលឃើញយាយថែមទេ?

ណោង ៖ អត់សោះ ។

ដានី ៖ ចុះយាយថែមធ្វើអី?

ណោង ៖ គេថាប្រធានធំនៅនឹងកន្លែងត្រពាំងថ្មនោះឯង ។

ដានី ៖ នៅធ្វើប្រធានធំនៅអាងត្រពាំងថ្ម?

ណេង : ចា៎! ទាស់តែកាច ថាអី ក៏មិនដែលមកដល់កន្លែងខ្ញុំទេ ឮគេថាកាច យើងចេះតែខ្លាចៗគេវ៉ៃ ចោល ។

ដានី : ចុះមីងអត់ដែលឃើញមុខយាយថែម?

ណេង : អត់ ដឹងមុខយាយថែមយ៉ាងណាទេ ។

ដានី : អត់ដឹងកន្លែងគាត់នៅណា?

ណេង : ទេ! មិនដឹងទេ ដូចមមាចចេះចុះ ។

ដានី : ចុះមីងដល់ពេលយើងវែកដីនៅត្រពាំងថ្មនឹងយើងសម្រាកនៅណា?

ណេង : សម្រាកនៅមាត់ទំនប់ដេកនឹងរោង គេធ្វើរោងដេក ។

ដានី : គេធ្វើរោង មានកន្ទេល មានខ្នើយ មានមុងដែរអត់?

ណេង : ទេ! អ្នកណាមាន អ្នកណាមិនមានក៏ដេកសំពត់កៅស៊ូដេកក្រោម ធ្វើម៉េចឲ្យតែរស់ ។ ខ្ញុំបើរឿងត្រពាំងថ្ម ខ្ញុំដឹនិត ខ្ញុំប្រាប់ឲ្យហើយ ។

ដានី : ចុះមីងធ្វើការនៅត្រពាំងថ្ម ប៉ុន្មាន រយៈពេលប៉ុន្មាន?

ណេង : ខ្ញុំធ្វើ៤ខែ ។

ដានី : ធ្វើ៤ខែ?

ណេង : ចា៎!

ដានី : ធ្វើការនៅ៤ខែ?

ណេង : ៤ខែ គេដកមកចំការកប្បាស និងកងវ៉ាភ្នំបាក់ ព្រោះខ្ញុំអ្នកចំការកប្បាស ។

ដានី : ដកមីង ដល់ពេល៤ខែគេដកមីង?

ណេង : ដកមកវិញ ។

ដានី : គេធ្វើហើយ ឬមិនទាន់ហើយ?

ណេង : កាលខ្ញុំមកអត់ទាន់មកទេ នៅខាងភ្នំកូនខ្វែង យើងមកនៅដើង ទៅចេះស្រុកស្ដីទេភ្លេចហើយ ។

ដានី : ចឹងទៅតែ៤ខែទេ មីងដកមកវិញ?

ណេង : ដកមកវិញ ។

ដានី : ដកមកកន្លែងចំការកប្បាស?

ណេង : ចា៎! ចំការកប្បាស ដល់ពេលដាំវិញ កងវ៉ា ភ្នំបាក់ សួរចុះសព្វថ្ងៃកើតដុះ ។

ដានី : ចឹងមីងដកមកវិញ មកនៅកងវ៉ាបានប៉ុន្មាន បាន?

ណោង ៖ កងវ៉ាខ្ញុំនៅម៉ាឆ្នាំកន្លះតាំងពីបដិវត្តខ្ញុំមិនដែលបានជួបម៉ែខ្ញុំទេ ។

ដានី ៖ អត់ទេមីង ប៉ុន្តែដល់ពេលមីងដកពីកន្លែងត្រពាំងថ្មមកវិញ មកកន្លែងកប្បាសវិញ រយៈពេលប៉ុន្មានទៀតទៅ បានយួនចូល?

ណោង ៖ ដឹងប៉ុន្មានកូន កាលនោះខ្ញុំគេដកមកដាំកន្លែងមាត់ស្ទឹង ។ ដល់យួនមកនេះ ខ្ញុំប្រាប់ដំណើរយួនមកចាប់ខ្ញុំចង់នឹង បៀតនឹងគុម្ពស្បូវ គេថាពួកខ្ញុំនិរតី ខ្ញុំថាមិនមានទេ ខ្ញុំចល័តដាំបន្លែទេ ដកខ្ញុំបៀតសែសិននោះ ដកចង់នោះ ។

ដានី ៖ ទៅសែសិន?

ណោង ៖ ចា៎!

ដានី ៖ ដកទៅកន្លែងសែសិននឹង?

ណោង ៖ ដកចង់ នែក!ខ្ញុំរត់ដាំបន្លែ គេខ្ញុំចោលស្តីខ្ញុំចោល ខ្ញុំរត់តាមគេដែលពួកនិរតីហៅទៅ ខ្ញុំចេះតែទៅ ។

ដានី ៖ ប៉ុន្តែខ្ញុំចង់ដឹងថាមីងមកពីកន្លែងត្រពាំងថ្មនឹង បានប៉ុន្មានបានយួនមកចាប់?

ណោង ៖ មិនដឹងប៉ុន្មានទេ អត់ច្បាស់ ។

ដានី ៖ យូរហើយឆាប់?

ណោង ៖ ដូចយូរគ្រាន់ ។

ដានី ៖ មកនឹងពេលដាំកប្បាស?

ណោង ៖ នៅ ។

ដានី ៖ ពេលយើងដកពីត្រពាំងថ្មមកនឹង អត់ទាន់ដាំកប្បាសទេ?

ណោង ៖ នៅៗ ។

ដានី ៖ ខែណាគេដកមីងមក?

ណោង ៖ ខែ១១គេបេះកប្បាសហើយណា ខែ៦ខែ៧ពេញកប្បាស ពេញដង្ហូវ ។

ដានី ៖ ពេលមីងដកមកពីត្រពាំងថ្មនឹង ពេលណា?

ណោង ៖ អឺ! ភ្លេចអស់ហើយកូន ។

ដានី ៖ ពេលគេបេះកប្បាស ឬពេលកប្បាស?

ណោង ៖ បេះរួចហើយ ខ្ញុំបេះរួច បានគេស្នើយើងទៅ អាខែប្រាំងយើង ។

ដានី ៖ ប៉ុន្តែមីងត្រឡប់មកពីអាងត្រពាំងថ្មវិញ?

ណោង ៖ មិនដឹងទេ ។

ដានី ៖ ពេលមកកន្លែងចំការកប្បាសវិញ ពេលនឹងកប្បាសកំពុងធ្វើអី?

ណោង ៖ កប្បាសនោះមិនទាន់ដាំទេ ឆាប់ដើមហើយ ។

ដានី ៖ កប្បាសឆាប់ដើមខែណា ភាគច្រើន?

ណោង ៖ ខែ១២ៗ ខែ៥-៦នេះពេញដង្គូវ ។

ដានី ៖ ចឹងពេលមីងដកមកនេះ ពេលកប្បាសឆាប់ដើម?

ណោង ៖ អឺ! កូនដីងគេស្នើកម្ចាំងទៅលើកទំនប់ត្រពាំងថ្មនេះ កប្បាសបេះអស់ហើយចូលឃ្លាំងអស់ហើយ ។

ដានី ៖ ចុះពេលមកវិញ?

ណោង ៖ មកវិញនេះ ភ្ជួរដីចាប់ដាំទៀតហើយ ដឹងមកពីណា ។

ដានី ៖ ចឹងពេលមីងមកពីត្រពាំងថ្មវិញ ពេលភ្ជួរដីចាប់ដាំកប្បាស?

ណោង ៖ ដាំទៀត ។

ដានី ៖ ខែណានឹង?

ណោង ៖ ខែ១-២ដាំដូចយើងបេះ ។

ដានី ៖ ចុះមីងដាំកប្បាសនឹង ពេលវៀតណាមយួនចូលមកនឹង កប្បាសកំពុងយ៉ាងម៉េច?

ណោង ៖ ដែលយួនចូលមកនោះ កប្បាសនោះកំពុងប្រហែល៧ខែៗ គេដកខ្ញុំទៅដាំបន្លែមាត់ស្ទឹងបេះបានខ្ញុំអត់ដឹង ។

ដានី ៖ ចឹងកប្បាសបានខែប៉ុន្មាន ៧ខែ?

ណោង ៖ ខែ៥ ដង្គូវប៉ុនៗនេះ ខែ៥-៦កប្បាសប៉ុននេះហើយ អាធុងប៉ុនសល់តែ១៨០ដាក់ឡើងដាក់ ។

ដានី ៖ ចុះពេលដែលយួនចូលមកនឹង កប្បាសកំពុងតែ ដង្គូវនៅ ដង្គូវរួច?

ណោង ៖ មិនដឹង ដែលខ្ញុំគេដកយកទៅដាំបន្លែ អានេះយើងនិយាយតាមដឹង ។

ដានី ៖ ពេលគេដកមីងទៅដាំបន្លែនឹង ពេលនឹងកប្បាសយ៉ាងម៉េច?

ណោង ៖ កប្បាសកំពុងស្មើនេះ ។

ដានី ៖ កប្បាសកំពស់នេះនឹង?

ណោង ៖ ដាក់ៗផ្លែហើយ ។

ដានី ៖ ចុះមីងអាពេលកប្បាសដែលដាក់នឹងខែប៉ុន្មាន?

ណោង ៖ ខែ៥ ចាប់ដង្គូវហើយ ផ្លែប៉ុនៗនេះ ។

ដានី ៖ ចឹងពេលគេដកមីងមក?

ណេង ៖ ដក ដាំបន្លែ។

ដានី ៖ ដាំបន្លែបានរយៈពេលប៉ុន្មាន បាន?

ណេង ៖ ប្រហែល២ខែ ស្តេកាស៊ីន(រោងបាយ)គេប៉ុនៗនេះហើយ ស្តេកាស៊ីនខ្ញុំដាំបន្លែ គោគេឲ្យម៉ានីម ខ្ញុំនិយាយឲ្យអស់។

ដានី ៖ ចឹងពេលដែលយួនចូលមក ចាប់មីងចងរយៈពេលប៉ុន្មាន?

ណេង ៖ ខ្ញុំរត់តាមពួកនិរតី។

ដានី ៖ រត់តាមពួកនិរតី?

ណេង ៖ ចាំ! នៅបៀតសំរោង.....។

ដានី ៖ ម៉េច?

ណេង ៖ សំរោង អង្គ្រែយើងខាងលិចសាលាក្រហមយើងទៅដល់គេមក។

ដានី ៖ ចឹងមីងខ្ញុំអរគុណមីងច្រើន។

ណេង ៖ ចាំ!

«ចប់»